**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្ដាល

លេខ : ០៣/១៦ សណ.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

*រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៦*

# សេចក្តីកំណត់
# ស្តីពីតួនាទី ភារកិច្ច រចនាសម្ព័ន្ធចាត់តាំង
# នៃគណៈឃោសនាអប់រំរាជធានី ខេត្ត និងគណៈឃោសនាអប់រំក្រុង ស្រុក ខណ្ឌ

**យោង** : - សេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល លេខ ០៨/០៥ សរ.គក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥ ស្តីពីតួនាទី ភារកិច្ច អង្គការចាត់តាំងនៃគណៈឃោសនាអប់រំគណៈកម្មាធិការកណ្តាល
- សេចក្តីកំណត់របស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល លេខ ៦៥ សណ.គក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០០ ស្តីពីតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មាធិការគណបក្ស ខេត្ត ក្រុង
- សេចក្តីកំណត់របស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលលេខ ៦៦ សណ.គក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០០ ស្តីពី តួនាទី ភារកិច្ច អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈឃោសនាអប់រំ ខេត្ត ក្រុង និងផ្នែកឃោសនាអប់រំ ស្រុក ខណ្ឌ
- សំណូមពរភារកិច្ចបច្ចុប្បន្ន
- ស្មារតីអង្គប្រជុំគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៦ ។

## គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល

ចេញសេចក្តីកំណត់ស្តីពីតួនាទី ភារកិច្ច រចនាសម្ព័ន្ធចាត់តាំងនៃគណៈឃោសនាអប់រំរាជធានី ខេត្ត និងគណៈឃោសនាអប់រំក្រុង ស្រុក ខណ្ឌ ដូចខាងក្រោម :

### I- តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងនៃគណៈឃោសនាអប់រំ រាជធានី ខេត្ត :

### ១ - តួនាទី និងភារកិច្ច

**ក**-គណៈឃោសនាអប់រំរាជធានី ខេត្ត ជាអង្គភាពជំនួយការផ្ទាល់នៃគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្នុងការដឹកនាំ ណែនាំ ជំរុញអនុវត្ត និងត្រួតពិនិត្យការអនុវត្តការងារឃោសនា និងអប់រំនយោបាយ សតិអារម្មណ៍របស់គណបក្ស នៅក្នុងរាជធានី ខេត្ត សំដៅកសាងពង្រឹងអង្គការចាត់តាំងគណបក្សបណ្តាថ្នាក់ បណ្តាផ្នែក បំផុសលើកទឹកចិត្តមន្ត្រីសមាជិកគណបក្ស និងមហាជន អនុវត្តកម្មវិធីនយោបាយ គោលការណ៍ គោលនយោបាយ និងសេចក្តីសម្រេចនានារបស់គណបក្ស ព្រមទាំងចូលរួមចំណែកក្នុងការអភិវឌ្ឍធនធានមនុស្សរបស់គណបក្ស ។

**ខ**-គណៈឃោសនាអប់រំរាជធានី ខេត្ត មានភារកិច្ច :

- ក្តាប់ជាប់កម្មវិធីនយោបាយ លក្ខន្តិកៈ គោលការណ៍ គោលនយោបាយ សេចក្តីសម្រេចនានា និងរាល់សមិទ្ធផលរបស់គណបក្ស កត្តាសត្យានុម័ត និងអត្តនោម័តក្នុងការអនុវត្តកម្មវិធីនយោបាយ ខ្លឹមសារណែនាំរបស់គណៈឃោសនាអប់រំនៃគណៈកម្មាធិការកណ្តាល និងសេចក្តីសម្រេចរបស់គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ដែលពាក់ព័ន្ធនឹងការងារឃោសនា អប់រំនយោបាយ សតិអារម្មណ៍។

- ខិតខំស្វែងយល់ វិភាគ និងវាយតម្លៃសភាពការណ៍សតិអារម្មណ៍របស់មន្ត្រី សមាជិកគណបក្ស និងមហាជន ហើយលើកមតិយោបល់ជូនគណៈកម្មាធិការគណបក្សពិនិត្យសម្រេចអំពីគោលការណ៍ ផែនការ ខ្លឹមសារ និងវិធានការឃោសនាអប់រំក្នុងជួរមន្ត្រី សមាជិកគណបក្ស និងក្នុងមហាជន។ បន្ទាប់ពីទទួលបានការសម្រេច ត្រូវជួយគណៈកម្មាធិការគណបក្សធ្វើការអប់រំ ផ្សព្វផ្សាយ គ្រើនរំលឹក ជំរុញការអនុវត្តរបស់គណបក្សនៅថ្នាក់នីមួយៗ និងផ្នែកនីមួយៗឲ្យមានប្រសិទ្ធភាព។

- តាមដានក្តាប់ជាប់សកម្មភាពឃោសនារបស់ក្រុមប្រឆាំង និងមជ្ឈដ្ឋានអគតិនានា ព្រមទាំងការផ្សព្វផ្សាយតាមបណ្តាញព័ត៌មានសង្គម ហើយលើកយោបល់ជូនគណៈកម្មាធិការគណបក្សអំពីគោល-ការណ៍ ទិសដៅ និងវិធានការឃោសនាវាយបក និងវាយលុកឲ្យបានទាន់ពេលវេលា ដើម្បីពង្រឹងប្រៀបរបស់គណបក្សនៅក្នុងសមរភូមិសតិអារម្មណ៍ និងសាធារណមតិ ។

- រៀបចំផែនការអប់រំនយោបាយដល់ជួរមន្ត្រីគណបក្ស និងសកម្មជនយុវជនគណបក្សនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងមូលដ្ឋានផ្សេងៗទៀត ដែលពុំបានមករៀននៅថ្នាក់កណ្តាល ជូនគណៈកម្មាធិការគណបក្សពិនិត្យ និងសម្រេច ។ ពង្រឹងកិច្ចសហការជិតស្និទ្ធជាមួយបណ្តាអង្គការចាត់តាំងរបស់គណបក្សនៅរាជធានី ខេត្ត ដើម្បីធានាឲ្យដំណើរការបើកវគ្គអប់រំនយោបាយទទួលបានលទ្ធផលល្អ។

- សហការជាមួយប្រព័ន្ធឃោសនាទូទៅ ពិសេសប្រព័ន្ធឃោសនា និងផ្សព្វផ្សាយរបស់គណបក្សនៅគ្រប់ថ្នាក់ ដើម្បីបង្កើនការងារឃោសនាផ្សព្វផ្សាយ និងអប់រំមហាជនឲ្យបានឆាប់រហ័ស ទាន់ពេល និងមានប្រសិទ្ធភាព។

- ជួយពង្រឹងសមត្ថភាពនយោបាយ និងមុខជំនាញរបស់គណៈឃោសនាអប់រំក្រុង ស្រុក ខណ្ឌ មន្ត្រីទទួលបន្ទុកការងារឃោសនាអប់រំនៃគ្រប់អង្គការចាត់តាំងមូលដ្ឋាន និងឃោសនិករបស់គណបក្ស ។

**២-រចនាសម្ព័ន្ធចាត់តាំង** :

**ក**- គណៈឃោសនាអប់រំ រាជធានី ខេត្ត ដឹកនាំដោយប្រធាន ១រូប និងមានអនុប្រធាន ២រូប ។

- ប្រធាន គឺជាមន្ត្រីគណបក្សដែលស្ថិតក្នុងជួរគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សរាជធានី ខេត្ត។

- អនុប្រធានមានភារកិច្ចជួយប្រធានក្នុងការដឹកនាំ ទទួលបន្ទុកការងារដែលប្រធានប្រគល់ឲ្យ និងជំនួសប្រធាននៅពេលប្រធានអវត្តមានតាមការប្រគល់ភារកិច្ចរបស់ប្រធាន ។

**ខ**- គណៈឃោសនាអប់រំរាជធានី ខេត្ត មាន ៣ ការិយាល័យចំណុះ គឺ : **ការិយាល័យរដ្ឋបាល ការិយាល័យឃោសនា និងការិយាល័យអប់រំនយោបាយ**

- **ការិយាល័យរដ្ឋបាល មានភារកិច្ច** :
  - \+ ការងារលិខិតស្នាមចេញ-ចូល
  - \+ ការងារផែនការហិរញ្ញកិច្ច
  - \+ ការងារបុគ្គលិក
  - \+ ការងារបូកសរុប
  - \+ ការងារគ្រប់គ្រងថែរក្សាឯកសារ ។
- **ការិយាល័យឃោសនា មានភារកិច្ច** :
  - \+ រៀបចំកម្មវិធីអប់រំ ផ្សព្វផ្សាយឯកសារនានារបស់គណបក្សដល់មន្ត្រី សមាជិកគណបក្ស និងមហាជន
  - \+ តាមដានក្តាប់ជាប់សភាពការណ៍សតិអារម្មណ៍ក្នុងគណបក្ស និងមហាជន ព្រមទាំងសកម្មភាពឃោសនារបស់ពួកអមិត្ត និងមជ្ឈដ្ឋានអគតិនានា ហើយកសាងឯកសារសម្រាប់ផ្សព្វផ្សាយអប់រំ និងវាយលុកក្នុងសាធារណមតិឲ្យបានទាន់ពេលវេលា
  - \+ រៀបចំផែនការបំពាក់បំប៉នបាឋកថា និងឃោសនិករបស់គណបក្សរាជធានី ខេត្ត
  - \+ តាមដាន ជំរុញការងារឃោសនា អប់រំនយោបាយសតិអារម្មណ៍របស់គណបក្សបណ្តាថ្នាក់ បណ្តាផ្នែក លើកកម្ពស់ចរិតមហាជន ចរិតវាយសំរុក និងចរិតជាប់មិនដាច់នៃការឃោសនា
  - \+ ចូលរួមរៀបចំគេហទំព័ររបស់គណបក្ស តាមដានការផ្សព្វផ្សាយតាមបណ្តាញព័ត៌មានសង្គម រៀបចំខ្លឹមសារសម្រាប់ឃោសនា ផ្សព្វផ្សាយ និងវាយបកតាមបណ្តាញព័ត៌មានសង្គម ។
- **ការិយាល័យអប់រំនយោបាយ មានភារកិច្ច** :
  - \+ លើកផែនការអប់រំ បំពាក់បំប៉ននយោបាយដល់មន្ត្រី និងសកម្មជនយុវជននៃគណបក្សបណ្តាថ្នាក់ បណ្តាផ្នែក ចំណុះគណបក្សរាជធានី ខេត្ត តាមគោលការណ៍ណែនាំរបស់ថ្នាក់កណ្តាល និងការណែនាំរបស់គណៈកម្មាធិការគណបក្សរាជធានី ខេត្ត
  - \+ រៀបចំកម្មវិធី ខ្លឹមសារសម្រាប់បំពាក់បំប៉ននយោបាយតាមការចាំបាច់ ក្រៅពីឯកសារដែលថ្នាក់កណ្តាលផ្តល់ឲ្យ
  - \+ គ្រប់គ្រងដំណើរការវគ្គអប់រំនយោបាយ និងតាមដានវាយតម្លៃលទ្ធផលនៃវគ្គសិក្សានីមួយៗប្រកបដោយភាពសត្យានុម័ត។
  - \+ កសាងជួរគ្រូឧទ្ទេសនាមបម្រើការងារអប់រំនយោបាយតាមបណ្តាថ្នាក់
  - \+ លើកគម្រោងផែនការចំណាយ សម្រាប់វគ្គអប់រំនយោបាយនីមួយៗ ។
- ការិយាល័យនីមួយៗមានប្រធាន ១រូប អនុប្រធាន ១រូប និងមន្ត្រី ១ ទៅ ២រូប ។

**គ**- ប្រធាន និងអនុប្រធាននៃគណៈឃោសនាអប់រំរាជធានី ខេត្ត ត្រូវបែងចែកភារកិច្ចគ្នាទទួលបន្ទុកដឹកនាំផ្ទាល់ ជាប្រធានការិយាល័យនីមួយៗ។

**ឃ**- ការរៀបចំមន្ត្រីនៃគណៈឃោសនាអប់រំរាជធានី ខេត្ត ទាំងមន្ត្រីដឹកនាំ និងមន្ត្រីជំនាញ ត្រូវជានាអំពីសមត្ថភាព កាយសម្បទា និងនិរន្តរភាពនៃការងារឃោសនាអប់រំ ហើយចៀសវាងការប្រគល់ភារកិច្ចឲ្យមន្ត្រីដែលមិនអាចបម្រើការងារនេះបាន។

II. **គណៈឃោសនាអប់រំ ក្រុង ស្រុក ខណ្ឌ** ៖

- គណៈឃោសនាអប់រំក្រុង ស្រុក ខណ្ឌ គឺជាអង្គភាពជំនួយការផ្ទាល់របស់គណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ លើការងារឃោសនា អប់រំនយោបាយ សតិអារម្មណ៍ ។

- គណៈឃោសនាអប់រំក្រុង ស្រុក ខណ្ឌ មានភារកិច្ចប្រហាក់ប្រហែលគណៈឃោសនាអប់រំរាជធានី ខេត្ត តែអនុវត្តភារកិច្ចក្នុងក្របខណ្ឌក្រុង ស្រុក ខណ្ឌ ជាកម្លាំងជួរមុខក្នុងសមរភូមិសតិអារម្មណ៍ ដែលត្រូវមានទំនាក់ទំនងផ្ទាល់ និងជាប្រចាំជាមួយកម្លាំងឃោសនានៅមូលដ្ឋាន (សកម្មជន ឃោសនិក មេខ្យល់) ។

- គណៈឃោសនាអប់រំក្រុង ស្រុក ខណ្ឌ ដឹកនាំដោយប្រធាន ១រូប ដែលជាមន្ត្រីនៅក្នុងជួរគណៈ-អចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ មានអនុប្រធាន ១ រូប និងមន្ត្រីជំនាញមិនលើសពី ៣រូប ។

- គណៈឃោសនាអប់រំក្រុង ស្រុក ខណ្ឌ មានពីរផ្នែកចំណុះ គឺ ផ្នែកឃោសនា និងផ្នែកអប់រំនយោបាយ ។

ប្រធាន និងអនុប្រធានត្រូវបែងចែកភារកិច្ចដឹកនាំផ្ទាល់ផ្នែកនីមួយៗ។

សេចក្តីកំណត់ខាងលើមានចរិតជាគោលការណ៍ទូទៅសម្រាប់ការអនុវត្ត ។ គណបក្ស រាជធានី ខេត្ត នីមួយៗត្រូវអនុលោមទៅតាមស្ថានភាពជាក់ស្តែង ដើម្បីរៀបចំអង្គការចាត់តាំងគណៈឃោសនាអប់រំរាជធានី ខេត្ត និងគណៈឃោសនាអប់រំក្រុង ស្រុក ខណ្ឌ ឲ្យជានាបានគុណភាព ប្រសិទ្ធភាព និងនិរន្តរភាពនៃការងារ។

ខុទ្ទកាល័យ គណៈចាត់តាំង គណៈឃោសនាអប់រំនៃគណៈកម្មាធិការកណ្តាល គណៈកម្មា-ធិការគណបក្សរាជធានី ខេត្ត និងបណ្តាផ្នែកពាក់ព័ន្ធមានភារៈអនុវត្តសេចក្តីកំណត់នេះ ។

**ជ.គណៈអចិន្ត្រៃយ៍ ៥**

**អនុប្រធាន**

**សាយ ឈុំ**

**កន្លែងទទួល** ៖

- ខុទ្ទកាល័យគណៈកម្មាធិការកណ្តាល
- គណៈចាត់តាំងគណៈកម្មាធិការកណ្តាល
- គណៈឃោសនាអប់រំគណៈកម្មាធិការកណ្តាល
- គណៈហិរញ្ញវត្ថុគណៈកម្មាធិការកណ្តាល
- គណៈកម្មាធិការគណបក្សរាជធានី ខេត្ត
- ឯកសារ